# រដ្ឋាភិបាលសន្យាថា៖ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនឹងមានស្តង់ដារដូចអន្តរជាតិនៅឆ្នាំ២០១៥



*លោករដ្ឋមន្ត្រីគាត ឈន់ ថ្លែងទៅកាន់សិក្ខាកាមចូលរួមពិភាក្សាអំពីការធ្វើកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងថវិកា (រូបថត៖គន្ធា)*

ភ្នំពេញ ៖ លោកទេសរដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសនៅថ្ងៃសុក្រទី១៥ ខែធ្នូនេះថា ចក្ខុវិស័យរយៈពេលវែងរបស់រដ្ឋាភិបាលគឺធ្វើយ៉ាងណាដើម្បីបង្កើនកម្រិតស្តង់ដារនៃ «ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របទៅនឹងកម្រិតស្តង់ដារអន្តរជាតិ ឬយ៉ាងហោចណាស់ឱ្យស្របនឹងកម្រិតស្តង់ដារក្នុងតំបន់នៅក្នុងឆ្នាំ២០១៥ ។ លោកបានប្រកាសផងដែរថា ឆ្នាំ២០០៧នេះ ជាឆ្នាំការឈានដល់ដំណាក់កាលទី២នៃការអនុវត្តន៍កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

លោកទេសរដ្ឋមន្ត្រីគាត ឈន់ បានថ្លែងប្រាប់ក្រុមមន្ត្រីដែលបានមកចូលរួមធ្វើសិក្ខាសាលាស្តីអំពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងថវិកានាថ្ងៃទី១៥ខែធ្នូឆ្នាំ២០០៦ថា ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលបានកំណត់គោលដៅយុទ្ធសាស្ត្រជា៤ជំហាន គឺទី១-ការបង្កើនភាពទុកចិត្តលើថវិកា ទី២-ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ ទី៣-ការបង្កើនការគាំទ្រនៃថវិកាចំពោះគោលនយោបាយរបស់រដ្ឋាភិបាល និងទី៤-ការបង្កើនគណនេយ្យភាពនៃម្ចាស់ថវិកាចំពោះលទ្ធផល ។

គួររំលឹកកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន នៅថ្ងៃទី៥ធ្នូឆ្នាំ២០០៤ ដែលប្រទេសម្ចាស់ផ្តល់ជំនួយជាច្រើនបានចូលរួមគាំទ្រនូវកំណែទម្រង់នេះ ។

លោកគាត ឈន់ មានប្រសាសន៍ថា កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅដំណាក់កាល ១ គឺភាពទុកចិត្តបាននៃថវិកាបានបញ្ចប់ហើយ ក្រោយពីបានអនុវត្តជិត ២ឆ្នាំមក ហើយឥឡូវយើងបានឈានទៅចាប់ផ្តើមដំណាក់កាលទី២ គឺប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ ។ លោកមានប្រសាសន៍ថា ដូច្នេះការងារថ្មីដែលយើងត្រូវផ្សព្វផ្សាយនឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៧ខាងមុខនេះ រួមមានការដាក់ឱ្យអនុវត្តប្លង់គណនេយ្យ និងមាតិកាគណនេយ្យថ្មី ការកែលំអនីតិវិធី ការរៀបចំថវិកា ការដាក់ឱ្យអនុវត្តវិធានផ្នែកសេដ្ឋកិច្ច ការចាប់ផ្តើមអនុវត្តសាកល្បងថវិកាតាមកម្មវិធីថ្មីសម្រាប់ក្រសួងចំនួន៧ ការកែលំអនីតិវិធីនៃការផ្តល់ធានាចំណាយ និងការទូទាត់ និងការដាក់ឱ្យអនុវត្តផែនការលទ្ធកម្មសាធារណៈ។

លោកមានប្រសាសន៍ថា ក្នុង រយៈពេលជិត២ឆ្នាំកន្លងមកនេះ (ដំណាក់ទី១) យើងបានធ្វើការកែលំអជាច្រើនទៅលើការអនុវត្តន៍ថវិកា ដូចជាការធ្វើវិសហមជ្ឈការត្រួតពិនិត្យហិរញ្ញវត្ថុ ការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ការកែលំអនិងកាត់បន្ថយនីតិវិធីចំណាយ ការដាក់ឱ្យអនុវត្តកម្មវិធីចំណូលចំណាយប្រចាំត្រីមាស និងការពង្រឹកការគ្រប់គ្រងសាច់ប្រាក់ជាដើម ។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ២០០៥កន្លងទៅនេះ ការអនុវត្តន៍ថវិកាមានលក្ខណៈល្អប្រសើរជាងឆ្នាំមុនៗ ជាក់ស្តែងយើងសម្រេចបានចំណូលខ្ពស់ជាងផែនការ ការគ្រប់គ្រងសាច់ប្រាក់មានលក្ខណៈល្អប្រសើរជាងមុន ការបើកផ្តល់សាច់ប្រាក់បានទៀងទាត់ពេលវេលាជាងមុន ហើយបំណុលសាច់ប្រាក់ដែលកកស្ទះនៅរតនាគារក៏ត្រូវបានកាត់បន្ថយដែរ ។ ទន្ទឹមនេះការអនុវត្តន៍ថវិកាឆ្នាំ២០០៦នេះនឹងកាន់តែទទួលបានលទ្ធផលល្អប្រសើរជាងឆ្នាំ២០០៥បន្ថែមទៀត ៕

ស៊ា សុខាំង